# ទំនៀមស្រុកខ្មែរក្នុងខែភ្ជុំបិណ្ឌ

ក្នុងសង្គមខ្មែរ "ភ្ជុំ" ឬ "ភ្ជុំបិណ្ឌ" ជាឱកាសធ្វើបុណ្យដែលមានរយៈពេលវែង រហូតដល់កន្លះខែ ពោលគឺចាប់ពីថ្ងៃ១រោច ដល់ថ្ងៃ១៥រោច ក្នុងខែភទ្របទ។ បុរាណលោកទុកភ្ជុំបិណ្ឌជាប្រពៃណីខ្មែរ មានលក្ខណៈជាបុណ្យគោរពវិញ្ញាក្ខន្ធបុព្វបុរស ញាតិសន្តានដែលចែកស្ថានទៅ ពោលគឺពុំមែនជាបុណ្យអបអរសាទរកម្សាន្តសប្បាយឡើយ។[1] តាមទំនៀម ទាំងព្រះមហាក្សត្រនិងប្រជារាស្ត្រ តែងចាត់ចែងខ្វាយខ្វល់សាងព្រះរាជកុសល និងកុសលឥតបីធ្វេស ថ្វាយនិងឧទ្ទិសដល់អស់សព្វសត្វសន្តាន ឱ្យបានរួចចាកទុក្ខ បានចាប់កំណើតក្នុងទីដ៏ប្រសើរ។ ក្នុងរយៈកាលភ្ជុំបិណ្ឌនេះសោត គេសង្កេតឃើញមានព្រះរាជពិធីរៀបចំប្រារព្ធក្នុងព្រះបរមរាជវាំង និងកិច្ច ឬពិធីតូចធំ រួមទាំងល្បែងរបាំផ្សេងៗប្រារព្ធនិងលេងតាមជំនឿ និងទម្លាប់នៃមបណ្ដាស្រុកនានាផង។

ជាការពិត បើរំឭកឫសគល់បុណ្យភ្ជុំបិណ្ឌ គេតែងលើកសំអាងប្រកពស្រដៀងគ្នាដោយយោងគម្ពីរបេតវត្ថុ គម្ពីរធម្មបទដ្ឋកថា សាស្ត្រាវិជ្ជាធរ និងសាស្ត្រាអានិសង្សបិណ្ឌ ដែលនិទានអំពីពួកប្រេត បាយបិណ្ឌ បាយបត្តបូរ និងផ្កាបិណ្ឌជាដើម។[2] ប៉ុន្តែអ្នកស្រាវជ្រាវវិជ្ជាបុរាណយល់ថា ភ្ជុំបិណ្ឌខ្មែរទទួលឥទ្ធិពលពិធី "គ្រាទ្ធ" *[śrāddha]* (ស្រាទ្ធ) របស់ឥណ្ឌា ដែលប្រារព្ធក្នុងរនោច ខែភទ្របទ។[3] ពាក្យគ្រាទ្ធ គេឃើញលេចឡើងក្នុងសិលាចារឹកចាប់ពីរវាងចុងសតវត្សទី៩ ដូចជា *K.279c, K.262, K.669, K.220* និង *IMA-3* ជាដើម។ ចំពោះសិលាចារឹកថ្នល់បារាយណ៍ *(K.279c)* ចារក្នុងរាជ្យព្រះបាទយសោវរ្ម័នទី១ (៨៨៩-៩០០) មានសេចក្ដីរៀបរាប់ពិធីបោះបាយបិណ្ឌឧទ្ទិសដល់អ្នកស្លាប់ ដើម្បីអាចចាប់ជាតិថ្មីបាន។ រីឯសិលាចារឹកសម័យកណ្ដាល *(IMA-3)* ចារក្នុងរាជ្យព្រះបាទជ័យជេដ្ឋាទី១ (១៥៧៦-១៥៩៤) មានឃ្លានិយាយពីការធ្វើពិធី "សរាទកាល" និង "តប្បំណទ្វាទសបិណ្ឌ" ដែលអ្នកស្រាវជ្រាវយល់ថា "សរាទកាល" គឺជាបុណ្យ "គ្រាទ្ធ" ឬភ្ជុំបិណ្ឌ

---

[1] ម៉ែន ប្រាង និង អាំ ឆន ១៩៩៤: ៤៥

[2] ចាប ពិន ១៩៦០: ៨៣, ម៉ែន ប្រាង និង អាំ ឆន ១៩៩៤: ៤៥-៥៣

[3] បទបង្ហាញអំពី ពីពិធី "គ្រាទ្ធ" របស់ឥណ្ឌាមកបុណ្យ "ភ្ជុំបិណ្ឌ" ដោយលោក ស៊ីយ៉ុន សុភារិទ្ធ រៀបចំដោយអង្គការយសោធរ ថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១៧

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

ហើយ "តប៉្បណទ្វាទសបិណ្ឌ" មានន័យថា "បិណ្ឌទី១២" ដែលព្រះរាជាតែងធ្វើព្រះរាជពិធីកាន់បិណ្ឌ និង "ចាក់ទឹកដូងថ្វាយព្រះបិតរ" ដូចទំនៀមក្នុងព្រះបរមរាជវាំងសព្វថ្ងៃ (រូបលេខ១-៣)។



រូបលេខ១-៣ ព្រះរាជពិធីចាក់ទឹកដូងថ្វាយព្រះបិតរក្នុងព្រះបរមរាជវាំង ឆ្នាំ២០១៥
(ប្រភព៖ www.norodomsihamoni.org)

តាមទំនៀមអ្នកស្រុកខ្មែរ ពីថ្ងៃ១រោច ដល់ថ្ងៃ១៤ រោច ហៅថា "កាន់បិណ្ឌ" ហើយថ្ងៃ ១៥ រោច ហៅថា "ភ្ជុំបិណ្ឌ"។ ចំណែកក្នុងព្រះបរមរាជវាំង តែប្រារព្ធព្រះរាជពិធីកាន់បិណ្ឌចាប់ពីត្រឹមថ្ងៃ១២ រោច ដល់ថ្ងៃ១៤ រោច ហើយនៅថ្ងៃ១៥ រោច គឺជាព្រះរាជពិធីចាក់ទឹកដូងថ្វាយព្រះបិតរ ដូចបញ្ជាក់មកខាងដើម។ លុះព្រឹកឡើង គឺកិច្ចបណ្តែតដំណាក់ព្រះបិតរក្នុងទន្លេចតុមុខ មុខព្រះបរមរាជវាំង។

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

ដោយឡែកចំពោះទំនៀមអ្នកស្រុក ការប្រារព្ធពិធីកាន់បិណ្ឌគឺចាប់ពីថ្ងៃ ១រោច រហូតដល់ថ្ងៃ១៥ រោច។ តាមទំនៀម ភូមិជាចំណុះវត្តនីមួយៗត្រូវដាក់ចែកវេនគ្នា ពោលគឺក្នុងន័យធ្វើមិនឱ្យដាច់ ហើយទុកពិធីនេះជាទំនៀមរួមរបស់សហគមន៍ ដែលមិនអាចធ្វើនៅផ្ទះបានឡើយ។ ចំពោះបាយបិណ្ឌតាមរបៀបអ្នកស្រុកសៀមរាប គេតែងនាំគ្នាទៅដេករៀបចំធ្វើនៅវត្ត តាមវេននីមួយៗ។ ការចែកវេនគ្នាកាន់បិណ្ឌបែបនេះជាទំនៀម ដែលអ្នកស្រាវជ្រាវពន្យល់ថា គឺក្នុងន័យមិនឱ្យបុណ្យនេះដាច់ក្នុងថ្ងៃណាមួយ នៃថ្ងៃទាំង១៥ ដ្បិតក្នុងជំនឿគឺធ្វើដើម្បីឱ្យព្រលឹងអ្នកស្លាប់នោះបានកើតនៅទីប្រសើរ។[4]

ឧទាហរណ៍មួយនៃការកាន់បិណ្ឌនៅវត្តស្វាតរំដែ ក្នុងស្រុកអង្គរធំ ខេត្តសៀមរាប មានកិច្ចសំខាន់ៗបួនគឺ ប្រុងពាលី សែនអ្នកតា សែនដូនតា និងនមស្ការព្រះរតន៍ត្រៃ សម្តែងធម្មទេសនា។[5] ប្រុងពលី គេរៀបចំធ្វើក្បែរសាលាឆាន់ក្នុងវេលាម៉ោងប្រហែល ៥ល្ងាច (រូបលេខ២៤)។ បន្ទាប់មក គេយកបាយម្ហូបនំចំណីសែនអ្នកតា (រូបលេខ២៥) រួចទើបធ្វើបាយបត្តបូរនិងពូតបាយបិណ្ឌ (រូបលេខ២៦) សែនដូនតា (រូបលេខ២៧) និងចម្រើនព្រះបរិត្ត សមាទានសីល សម្តែងធម្មទេសនា។[6]



រូបលេខ២៤ កិច្ចប្រុងពលី



រូបលេខ២៥ កិច្ចសែនអ្នកតានៅក្នុងវត្ត

---

[4] បទសម្ភាសរវាងលោក លី តារាវុធ និងសាស្ត្រាចារ្យ អាំង ជូលាន អំពី "បុណ្យភ្ជុំបិណ្ឌ" ផ្សាយថ្ងៃទី២៣ ខែមករា ឆ្នាំ២០២១ លើតំណ https://www.youtube.com/watch?v=LLDH7PYeKC4

[5] វត្តនៅតំបន់ខ្លះ គេមានកិច្ចលើកទង់នៅវេលារសៀល មុនប្រុងពលី

[6] ទំនៀមទេសន៍ក្នុងរដូវភ្ជុំនៅតាមស្រុកខ្លះ គេតែងឱ្យព្រះសង្ឃទាំងចាស់ទាំងក្មេងចាប់ឆ្នោតរើសថ្ងៃ សម្រាប់លើកយកធម៌មកសម្តែង។

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត



*រូបលេខ៦ ពូតបាយបិណ្ឌ*



*រូបលេខ៧ សែនដូនតានៅលើសាលាឆាន់*

ចំណែកការបោះបិណ្ឌ គឺគេតែងធ្វើនៅវេលាទៀបភ្លឺ ដែលគេជឿថាជាវេលាដែលពពួកប្រេតអាចទទួលយកបាយបិណ្ឌនោះបាន។ បាយបិណ្ឌដែលបោះនោះសោត តែងដាក់នៅជុំវិញព្រះវិហារ ឬក្បែរចេតិយ (រូបលេខ៨-៩) ដ្បិតពពួកប្រេត ឬសត្វនរកជាអមនុស្សដែលស្ថិតនៅមិនឆ្ងាយពីវត្តឡើយ។[7] មិនតែប៉ុណ្ណោះ នៅក្បែរព្រះវិហារវត្តខ្លះ គេតែងធ្វើរានយមរាជ (ឬនឹមរាជ) នៅទិសឦសាន ឬមុខព្រះវិហារសម្រាប់ដាក់ពំនូតបាយបិណ្ឌនោះ ឧទ្ទិសដល់ស្តេចយមរាជ (រូបលេខ១០)។ លើសពីនេះតាមការសិក្សារបស់អ្នកស្រី Eveline Porée-Maspero នៅក្នុងឆ្នាំ១៩៦៤បង្ហាញថា នៅក្នុងរដូវភ្ជុំបិណ្ឌនេះ អ្នកស្រុកស្ទោង ខេត្តកំពង់ធំ តែងយកបាយបិណ្ឌដាក់ក្នុងច្រំមួយ យកទៅដោតក្នុងស្រែ ក្នុងជំនឿថា ដើម្បីឱ្យស្រូវទទួលបានផលល្អ។[8]





*រូបលេខ៨-៩ បាយបិណ្ឌដែលបោះជុំវិញព្រះវិហារ*



*រូបលេខ១០ បាយបិណ្ឌនៅលើរានយមរាជ (?)*

[7] បទបង្ហាញអំពី "ភពអមនុស្សនៅក្នុងជំនឿខ្មែរ" ដោយសាស្ត្រាចារ្យ អាំង ជូលាន រៀបចំដោយអាជ្ញាធរជាតិអប្សរា នៅថ្ងៃទី៧ ខែមីនា ឆ្នាំ២០២២

[8] Eveline Porée-Maspero 1964: 327-328

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

ការធ្វើកិច្ច និងបោះបាយបិណ្ឌតាមថ្ងៃកាន់បិណ្ឌដូចរៀបរាប់ដោយសង្ខេបខាងលើ បេះតែបន្តរហូតតាមទំនៀមប្រចាំវត្តនីមួយៗ រហូតដល់ថ្ងៃ១៥ រោច ជាថ្ងៃភ្ជុំធំ ឬហៅថា ភ្ជុំបិណ្ឌ។ ក្នុងរវាងថ្ងៃចុងក្រោយនេះ គេឃើញមានទំនៀមផ្សេងៗប្លែកគ្នាតាមតំបន់។ បើលើកឧទាហរណ៍មួយក្នុងសហគមន៍ជនជាតិកួយក្នុងតំបន់រវាលវែង នៃខេត្តកំពង់ធំ គេតែងធ្វើកិច្ចសែនដែក នៅក្នុងព្រឹកថ្ងៃ១៤ រោច មុនយកចង្ហាន់ទៅវត្ត។ ក្នុងកិច្ចនោះ គេរៀបចំម្ហូមអាហារ បង្អែមចម្អាប កេសជ្ជៈ និងសម្លៀកបំពាក់ ជាដើមសម្រាប់ជាដង្វាយនិងជារណ្តាប់ (រូបលេខ១១-១២)។ រណ្តាប់ទាំងនេះរៀបឡើងសម្រាប់សែនដល់ឧបករណ៍ទាំងឡាយណាដែលធ្វើអំពីដែក ឬមានដែកនៅក្នុងនោះ ដូចជាកាំបិត ពូថៅ ដឹង រណា ចប ជំនីក ។ល។ ក្នុងថ្ងៃនោះ គេតមមិនយកសម្ភារៈនានាដូចរៀបរាប់ខាងលើមកប្រើឡើយ។[9] សូមរំឭកថា តាមការស្រាវជ្រាវ ជនជាតិកួយក្នុងស្រុករវាលវែង ជាក្រុមជនជាតិដើមភាគតិចមានជំនាញផលិតដែកតាំងពីបុរាណកាល។



រូបលេខ១១-១២ ទំនៀមសែនដែករបស់ជនជាតិកួយ ក្នុងថ្ងៃភ្ជុំបិណ្ឌ (រូបថត៖ គង់ វីរៈ)

រីឯនៅភូមិប្រាសាទ ឃុំឈូកខ្សាច់ ស្រុកបារាយណ៍ ខេត្តកំពង់ធំ ជាអតីតសហគមន៍ព្រាហ្មណ៍ ដែលមាននាទីថែរក្សាព្រះខ័ន (ព្រះខ័នស្តេចត្រាញ់) តពូជពង្សតំណពីបុរាណកាលមក។ តាមទំនៀម ព្រះខ័ននោះតែងដង្ហែយកមកធ្វើកិច្ចក្នុងព្រះរាជពិធីចាក់ទឹកដូងថ្វាយព្រះបិតរ ក្នុងព្រះបរមរាជវាំង។[10] តាមការសិក្សា ទំនៀមនេះបានបញ្ចប់នៅពេល

[9] គង់ វីរៈ ២០០៥-២០០៦: ៤៩-៥០

[10] ឈឹម ក្រសេម ១៩៦៩: ១២៨-១៣៨

អត្ថបទដោយ៖ ហឿន សុវណ្ណមរកត

មានរដ្ឋប្រហារឆ្នាំ១៩៧០ តែព្រះខ័ននោះត្រូវរក្សាក្នុងគ្រួសារព្រាហ្មណ៍ដដែល។ ក្រោយសង្គ្រាមបញ្ចប់ ព្រាហ្មណ៍ដែលមាននាទីរក្សាព្រះខ័នតែងធ្វើកិច្ចលាងព្រះខ័នពីរដងក្នុងមួយឆ្នាំ គឺចូលឆ្នាំ និងភ្ជុំ។ ប៉ុន្តែសព្វថ្ងៃ គេដឹងថាទំនៀមនេះពុំនៅធ្វើក្នុងគ្រួសារព្រាហ្មណ៍ផ្ទាល់ ហើយតែក្នុងពេលចូលឆ្នាំប៉ុណ្ណោះ (រូបលេខ១៣-១៤)។[11]





*រូបលេខ១៣-១៤ កិច្ចលាងព្រះខ័ននៃគ្រួសារព្រាហ្មណ៍នៅភូមិប្រាសាទ (រូបថត៖ ឯម គឹមស្រ៊ាង)*

ទោះយ៉ាងណាក្តី ទំនៀមខ្មែរទូទៅនៅក្នុងល្ងាចថ្ងៃ១៥ ពេលបន្ទាប់ពីត្រឡប់ពីវត្តវិញ នៅតាមផ្ទះនីមួយៗ គេតែងរៀបចំសែនដូនតា។ គ្រឿងសំណែនដូចជា ផ្លែឈើ ចេកទុំ នំចំណី ស្រា មាន់ស្ងោ ទឹកក្រូច បង្អែម ចម្អាប ព្រមទាំងបាយបិណ្ឌ បាយបត្តបូរ រៀបចំដាក់លើកម្រាល (រូបលេខ១៥-១៦)។ លុះរៀបចំស្រេចហើយគេអញ្ជើញចាស់ទុំ និងញាតិមិត្តអ៊ុជទៀនធូប អញ្ជើញដីដូនជីតាចែកឋានទៅ ចូលមកសេពសោយម្ហូបចំណីក្នុងឱកាសនេះ។ ពេលព្រេនចប់មួយបទ គេច្រូចស្រាទៅក្នុងចានសំណែនដោយឡែកមួយដែលមានដាក់លាយច្របល់គ្នាទាំងនំចំណី បង្អែម ចម្អាប និងផ្លែឈើ។ បន្ទាប់ពីព្រេនចប់ គេច្រើនសំណែននេះយកទៅចាក់ក្រោមជណ្តើរផ្ទះ ឬនៅជាយភូមិ ដែលគេយល់ថាសម្រាប់ពពួកអមនុស្សផ្សេងៗពុំមែនជាញាតិ។[12]

11 សរ សុធីតា ២០១៤: ២៩-៣៥ និង ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ២០១៧: ២០៨-២១១

12 ពេលខ្លះគេហៅពពួកអមនុស្សទាំងនោះថា "ពួកដោយពោយ"។

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត




រូបលេខ១៥-១៦ រណ្ដាប់រៀបចំដែនដូនតាក្នុងថ្ងៃភ្ជុំបិណ្ឌ

នៅព្រលឹមថ្ងៃ ១កើត ចូលខែអស្សុជ គេតែងរៀបចំជូនដូនតាទៅស្រុកវិញ។[13] រណ្ដាប់រួមមាន នំចំណី ផ្លែឈើ គ្រាប់ពោត គ្រាប់សណ្ដែក ល្ង អង្ករ អំបិល ម្រេច ខ្ទឹម ។ល។ ខ្ចប់ជាកញ្ចប់តូចៗដូចគ្រឿងបម្រុង ដាក់លើស្រទបចេកបត់មានសណ្ឋានដូចទូកបណ្ដែតតាមទឹក ហើយឧបកិច្ចថា "ទៅស្រុកទន្លេស្ងួតកន្ទួតមួយដើម" (រូបលេខ១៧)។ ក្នុងវេលានេះដែរ ចំពោះកសិករដែលប្រើគោរក្របីជាកម្លាំងអូសទាញ គេក៏មានកិច្ចសូមខមាទោសសត្វទាំងនោះ ដោយយកទៅលាងទឹក លាបប្រេង ចងអំបោះ ឲ្យស៊ីចេក និងនំ ហើយនិយាយសូមខមាទោស ដែលខ្លួនជាម្ចាស់ធ្លាប់វាយដំជេរប្រទេច ដឹកជញ្ជូនធ្ងន់ស្រាលកន្ទងមក (រូបលេខ១៨)។ ពេញមួយថ្ងៃនេះ គេពុំប្រើសត្វទាំងនោះឡើយ បើទោះជាការងារស្រែចម្ការពុំទាន់រួចរាល់ចប់សព្វគ្រប់ក្ដី។




រូបលេខ១៥-១៦ រណ្ដាប់រៀបចំដែនដូនតាក្នុងថ្ងៃភ្ជុំបិណ្ឌ

[13] ម៉ែន ប្រាង និង អាំ ឆន ១៩៩៤: ៤៦

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

ជារួមមក ទំនៀមភ្ជុំបិណ្ឌមានឫសគល់តាំងពីយូរអង្វែងមក ជាពិសេសទំនៀមក្នុងព្រះបរមរាជវាំង។ ប៉ុន្តែរបៀបរៀបចំ និងកិច្ចផ្សេងៗរួមបញ្ចូលក្នុងពិធីនេះខុសប្លែកគ្នាខ្លះតាមទម្លាប់។ ស្រុកភូមិខ្លះមានប្រារព្ធកិច្ចសំខាន់ៗក្នុងវេលានេះតាមទំនៀមដូចជា សែនដែក និងលាងព្រះខ័ន ដែលហាក់ដូចជាគំនិតរួមយល់ថា វត្ថុទាំងនោះមានគុណបំណាច់មានព្រលឹងថែទាំ ដែលត្រូវធ្វើកិច្ចតបស្នង។ លើសពីនេះ បើមើលតំបន់ដទៃខ្លះទៀត គេឃើញមានការលេងល្បែងផ្សេងៗក្នុងឱកាសភ្ជុំបិណ្ឌដែរដូចជា ប្រណាំងក្របី ប្រណាំងសេះ បោកចំបាប់នៅវត្តព្រះវិហារសួគ៌ ក្នុងខេត្តកណ្ដាលជាដើម៕

## ឯកសារយោង


ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ

២០១៧, *បញ្ជីសារពើភណ្ឌបេតិកភណ្ឌវប្បធម៌អរូបីកម្ពុជា*, ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ, ភ្នំពេញ

គង់ វីរៈ

២០០៥-២០០៦, "ពិធីសែនដែករបស់ជនជាតិកួយនៅភូមិវាលវែង", *បណ្ដាញព័ត៌មានវប្បធម៌ខ្មែរ*, លេខ១, ទំ.៤៩-៥០, Friends of Khmer Culture, ភ្នំពេញ

ចាប ពិន

១៩៦០, *ព្រះរាជពិធីទ្វាទសមាស*, ភាគ៣, ពុទ្ធសាសនបណ្ឌិត្យ, ភ្នំពេញ

ឈឹម ក្រសេម

១៩៦៩, *ព្រះរាជពិធីទ្វាទសមាស*, ភាគ១, ពុទ្ធសាសនបណ្ឌិត្យ, ភ្នំពេញ

ម៉ែន ប្រាង និង អាំ ឆន

១៩៩៤, "បុណ្យភ្ជុំបិណ្ឌ", *កម្ពុជសុរិយា*, ឆ្នាំទី៤៨, លេខ២, ទំ. ៤៥-៥៥, ពុទ្ធសាសនបណ្ឌិត្យ, ភ្នំពេញ

សរ សុធីតា

២០១៤, *សហគមន៍ព្រាហ្មណ៍នៅភូមិប្រាសាទ*, សារណាបញ្ចប់បរិញ្ញាបត្របុរាណវិទ្យា, សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ, ភ្នំពេញ

Ang Chouléan

1986. *Les êtres surnaturels dans la religion Populaire khmère,* Cedoreck, Paris

Éveline Porée-Masper

1964, *Étute sur les Rites Agraires des Cambodgiens,* Tome II, Mouton & Co, Paris


អត្ថបទដោយ៖ ហៀន សុវណ្ណមរកត